City of Seattle

Democracy Voucher Program

# ចាប់អារម្មណ៍ក្នុងការឈរឈ្មោះ សម្រាប់មុខតំណែងក្នុងការបោះឆ្នោត ទីក្រុង SEATTLE ឆ្នាំ 2025 ដែរទេ?

**ប្រើ Democracy Vouchers (ប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ) ដើម្បីផ្តល់មូលនិធិដល់យុទ្ធនាការរបស់អ្នក!**




## របៀបដែលកម្មវិធីនេះដំណើរការ

ក្នុងឆ្នាំ 2025, Seattle Ethics and Elections Commission (SEEC) នឹងចែក Democracy Vouchers(ប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ) ចំនួនបួនសន្លឹក ដែលប័ណ្ណនីមួយៗមានតម្លៃ $25 ទៅដល់ពលរដ្ឋនៅទីក្រុង Seattle ដែលមានសិទ្ធិ។

ពលរដ្ឋផ្តល់ប័ណ្ណទឹកប្រាក់ទាំងនេះជូនបេក្ខជនដែលចូលរួមដែលពួកគេគាំទ្រ។ SEEC ផ្ទៀងផ្ទាត់ប័ណ្ណទឹកប្រាក់ទាំងនេះ និងចេញថវិកាសម្រាប់យុទ្ធនាការ។

## ក្លាយជាបេក្ខជន

- ☑ រៀបចំកាលវិភាគបណ្តុះបណ្តាលមួយទល់មួយ។
- ☑ សន្យាធ្វើជាបេក្ខជន Democracy Voucher (ប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ)។
- ☑ ប្រមូល Democracy Vouchers (ប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ)ពីពលរដ្ឋនៅទីក្រុង Seattle។
- ☑ មានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីនេះ ដើម្បីទទួលបានមូលនិធិ។
- ☑ ផ្តល់មូលនិធិដល់យុទ្ធនាការរបស់អ្នក!

## សំណួរដែលគេសួរញឹកញាប់

**តើមានថវិកាប៉ុន្មានសម្រាប់យុទ្ធនាការ?**

សម្រាប់ឆ្នាំ 2025 មានទឹកប្រាក់ចំនួន $9 លានដុល្លារ សម្រាប់បេក្ខជនដើម្បីផ្តល់មូលនិធិដល់យុទ្ធនាការរបស់ពួកគេ។

**តើមុខតំណែងណាខ្លះដែលមានសិទ្ធិទទួលបានមូលនិធិ?**

តំណែងចៅហ្វាយក្រុង មេធាវីក្រុង និងតំណែងក្រុមប្រឹក្សាក្រុងមណ្ឌលទី 2, 8, និង 9។

**តើបេក្ខជនម្នាក់ៗអាចទទួលបានថវិកាប៉ុន្មាន?**

| ដែនកំណត់នៃការចំណាយសម្រាប់បេក្ខជនដែលចូលរួម | មេធាវីក្រុង | សមាជិកក្រុមប្រឹក្សាក្រុងទូទៅ | មណ្ឌលក្រុមប្រឹក្សាក្រុង | ចៅហ្វាយក្រុង |
|---|---|---|---|---|
| ដែនកំណត់នៃការចំណាយលើយុទ្ធនាការសម្រាប់ការបោះឆ្នោតបឋម | $225,000 | $225,000 | $112,500 | $450,000 |
| ដែនកំណត់នៃការចំណាយលើយុទ្ធនាការរួមបញ្ចូលគ្នាសម្រាប់ការបោះឆ្នោតបឋម និងការបោះឆ្នោតសាកល | $450,000 | $450,000 | $225,000 | $900,000 |

## ខ្លឹមសារសង្ខេបឆ្នាំ 2025

- **ថ្ងៃទី 1 ខែមករា ឆ្នាំ 2024** - វដ្តនៃការបោះឆ្នោតចាប់ផ្តើម។
- **ថ្ងៃទី 9 ខែមករា ឆ្នាំ 2025** - បេក្ខជនត្រូវតែបញ្ជាក់ឋានៈជានិវាសនជននៅទីក្រុង Seattle ត្រឹមកាលបរិច្ឆេទនេះ។
- **ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2025** - Democracy Vouchers (ប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ) ត្រូវបានផ្ញើតាមប្រៃសណីយ៍ ហើយបេក្ខជនអាចចាប់ផ្តើមប្រមូលប័ណ្ណទឹកប្រាក់ទាំងនេះបាន។
- **ថ្ងៃទី 5-9 ខែឧសភា ឆ្នាំ 2025** - បេក្ខជនទាំងអស់ត្រូវតែបំពេញសេចក្តីប្រកាសអំពីបេក្ខភាពជាមួយការបោះឆ្នោតនៅខោនធី King។
- **ថ្ងៃទី 23 ខែឧសភា ឆ្នាំ 2025** - នេះជាថ្ងៃចុងក្រោយដែលបេក្ខជនអាចសន្យាចូលរួម Democracy Voucher Program (កម្មវិធីប័ណ្ណទឹកប្រាក់ប្រជាធិបតេយ្យ)។
- **ថ្ងៃទី 5 ខែសីហា ឆ្នាំ 2025** - ថ្ងៃបោះឆ្នោតបឋម។
- **ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025** - ថ្ងៃបោះឆ្នោតសាកល។

## តើខ្ញុំចាប់ផ្តើមដោយរបៀបណា?

សូមទាក់ទងមកយើងខ្ញុំ ដើម្បីរៀបចំកាលវិភាគបណ្តុះបណ្តាលមួយទល់មួយ៖

**democracyvoucher@seattle.gov**

**(206) 727 - 8855**

**ពិនិត្យឡើងវិញនូវឯកសារនៅលើគេហទំព័រនៃបេក្ខជន និងធនធានយុទ្ធនាការរបស់យើង**

Khmer